## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
## អភិបូជាបុណ្យព្រះយេស៊ូប្រសូតនៅផ្សារតូច
## ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧
*ព្រះយេស៊ូជាព្រះពន្លឺ*

អត្ថបទទី១៖ អស ៩,១-៦
អត្ថបទទី២៖ ទត ២,១១-១៤
ដំណឹងល្អ៖ លក ២,១-១៤

បងប្អូនជាទីស្រឡាញ់!

ពេលនេះយើងជាគ្រីស្តបរិស័ទដែលដើរតាមព្រះយេស៊ូ យើងរួមគ្នាថ្វាយបង្គំព្រះយេស៊ូ ដែលកើតជាមនុស្ស។ នៅពេលខ្ញុំចូលក្នុងព្រះវិហារនេះ ខ្ញុំឃើញកន្លែងអសនៈថ្មី ស្អាតមែនទែន ល្មមដើម្បីថ្វាយអភិបូជាបុណ្យព្រះយេស៊ូប្រសូត។ អត្ថន័យនៃបុណ្យព្រះយេស៊ូប្រសូតគឺអី? ខ្ញុំបានរិះគិតពេលដើរមួយខែហើយ យើងបានទៅប្រទេសភូមាជួបជាមួយសម្តេចប៉ាបជាមួយគ្រីស្តបរិស័ទមួយចំនួន។ ទៅប្រទេសឡាវដែលជាប្រទេសកម្មុយនីស្ត មួយដើម្បីទទួលស្វាគមន៍លោកកាឌីណាល់ថ្មី។ នៅទីក្រុងភ្នំពេញយើងបានឃើញនៅគ្រប់ទីកន្លែង គេបានរៀបចំ Merry Christmas បានរៀបចំតុបតែងយ៉ាងស្អាត។ លក់ឥវ៉ាន់សម្រាប់បុណ្យណូអែល តាណូអែលនៅគ្រប់ទីកន្លែង និងដើមសាបុាំង យើងស្អាត់ដល់កំពូល។

យើងបានរៀបចំខ្លួនពិសេសមែនទែន គ្រប់ទីកន្លែងយើងឃើញពន្លឺ គ្រប់ទីកន្លែងយើងឃើញការតុបតែង គ្រប់ទីកន្លែងយើងឃើញកាដូរ Merry Christmas ប៉ុន្តែនៅថ្ងៃព្រះយេស៊ូប្រសូត អត់មានអីសោះ។ អត្ថន័យបុណ្យព្រះយេស៊ូប្រសូតបាត់អស់ហើយ។ ខ្ញុំជាមួយកូនក្មេងនៅសាលាឡាវ៉ាឡា កូនក្មេងពិការ ខ្ញុំបានសួរ ថ្ងៃនេះយើងប្រារព្ធបុណ្យអ្វី? គេឆ្លើយភ្លាមបុណ្យណូអែល ខ្លះថាបុណ្យគ្រីស្តម៉ាស។ និយាយមិចជាភាសាខ្មែរ? ប្រហែលគេមិនដឹងមានន័យដូចម្តេច។ បុណ្យព្រះយេស៊ូប្រសូត យើងជាគ្រីស្តបរិស័ទយើងដឹង។ យើងជាគ្រីស្តបរិស័ទ យើងទទួលបេសកកម្មមួយយ៉ាងពិសេស ដើម្បីឲ្យអត្ថន័យនៃបុណ្យព្រះយេស៊ូប្រសូត ដំណឹងល្អដែលក្រុមទេវទូតបានប្រកាស ដល់ក្រុមគង្វាលពីយប់មិញ ដំណឹងល្អ គឺថ្ងៃនេះមានព្រះសង្គ្រោះដែលកើតឡើង នៅក្នុងភូមិបេថ្លេហិម។ ថ្ងៃនេះយើងឃើញសញ្ញាមួយយ៉ាងពិសេស គឺទារកម្នាក់ដែលរុំសំពត់ក្នុងក្រោលគោ នេះជាអ្វីដែលយើងឃើញ។ យើងជាគ្រីស្តបរិស័ទ គឺជាសាក្សីបន្ទាល់ អំពីព្រះយេស៊ូប្រសូត អំពីអត្ថន័យ

នៃបុណ្យព្រះយេស៊ូប្រសូត។ អត្ថន័យនៃបុណ្យព្រះយេស៊ូប្រសូត គឺជាពន្លឺ ព្រះពន្លឺបានកើតជាមនុស្ស ព្រះបន្ទូលបានកើតជាមនុស្ស ព្រះពន្លឺដែលយាងមកដើម្បីបំភ្លឺភាពងងឹត នៃពិភពលោកទាំងមូល ហើយយើងជាសាក្សីនៃព្រះពន្លឺ។ យើងមិនមែនព្រះបន្លឺទេ យ៉ូហានបាទីស្ទបាននិយាយច្រើនដង "**ខ្ញុំមិនមែនពន្លឺទេ ប៉ុន្តែខ្ញុំបង្ហាញព្រះពន្លឺដែលកំពុងយាងមក**"។ ហោរាចារ្យដែលបានធ្វើដំណើរតាមផ្កាយ គេបានមើលពន្លឺហ្នឹង ដើម្បីទៅថ្វាយបង្គំដល់ទារកមួយ ដែលជាព្រះបុត្រា ដែលជាព្រះសង្គ្រោះ។ ព្រះពន្លឺយាងមក ដើម្បីបំភ្លឺភាពងងឹតនៃជីវិតរបស់យើង និងយើងជាគ្រីស្តបរិស័ទ នៅក្នុងដៃរបស់យើង នៅក្នុងដួងចិត្តរបស់យើង យើងទទួលព្រះពន្លេះនេះ ដើម្បីទៅជាសាក្សីនៃព្រះពន្លឺ។ យើងបានស្តាប់អំបាញមិញ នៅក្នុងអត្ថបទព្រះគម្ពីររបស់សន្តយ៉ូហាន គឺ "**ព្រះពន្លឺដែលយាងមក**"។ មនុស្សមិនចូលចិត្តពន្លឺ យើងចូលចិត្តភាពងងឹតស្ងាត់ ប៉ុន្តែថ្ងៃនេះព្រះពន្លឺយាងមក ដើម្បីបំភ្លឺភាពងងឹត កែប្រែភាពងងឹតទៅជាសេចក្តីសង្ឃឹម ដើម្បីកែប្រែកន្លែងដែលមានទុក្ខលំបាក ដែលមានអំពើបាប ទៅជាពន្លឺថ្មី និងជីវិតថ្មី ។

នៅក្នុងរដូងរងចាំ យើងបានស្តាប់យ៉ូហានបាទីស្ទ បានទៅប្រកាសដំណឹងល្អនៅវាលរហោស្ថាន នៅកន្លែងដែលគ្មានទឹក នៅកន្លែងគ្មានសត្វ នៅកន្លែងគ្មានដើមឈើ នៅកន្លែងដែលមានតែសត្វតិរិច្ឆាន សត្វពស់ សត្វសាហាវ។ កន្លែងដែលលោកយ៉ូហានបាទីស្ទបានប្រកាសដំណឹងល្អ ដើម្បីចង្អុលឲ្យគេមើលឃើញ បន្តិចទៀតព្រះពន្លឺយាងមកដើម្បីបំភ្លឺពិភពលោក ។ ថ្ងៃនេះយើងឮថា ព្រះយេស៊ូជាព្រះពន្លឺ ដើម្បីបំភ្លឺភាពងងឹត នៃពិភពលោក។ ថ្ងៃនេះយើងមើលឃើញជាក់ស្តែង វាលរហោស្ថាន ទៅជាដីមួយដែលជាដីអស្ចារ្យ ដែលមានដើមឈើ ដែលមានផ្កាដុះឡើង មានទឹកដែលហូរចេញ។ ថ្ងៃនេះយើងមើលឃើញនៅក្នុងភាពងងឹត នៃជីវិតរបស់យើង មានពន្លឺមួយយ៉ាងពិសេសអស្ចារ្យ ពន្លឺដ៏ត្រចះត្រចង់ដែលយើងយាងមកដើម្បីបំភ្លឺជីវិតរបស់យើង។ ដូច្នេះនៅក្នុងរដូវរង់ចាំ ដែលយើងបានធ្វើដំណើរ យើងចេញពីវាលរហោស្ថាន ដើម្បីចូលក្នុងសួនច្បារមួយយ៉ាងស្អាត ដែលមានដើមឈើ ដែលមានផ្កា ដែលមានទឹកហូរចេញ ដែលមានសត្វទាំងឡាយ ដែលមានមេអំបៅដែលមានបក្សាបក្សី ដែលពោរពេញដោយអំណរសប្បាយ។

នៅក្នុងរដូវរងចាំ យើងបានមើលឃើញភាពងងឹត នៃពិភពលោករបស់យើង ភាពងងឹតនៃជីវិតរបស់យើង ហើយយប់នេះយើងភ្លឺដល់កំពូល ដោយសារតែព្រះយេស៊ូដែល

យាងមក ដើម្បីណែនាំឲ្យពិភពលោករបស់យើងទៅជាពិភពលោកថ្មី នេះជាដំណឹងល្អដែលយើងទទួល។ នៅក្នុងយប់ដ៏សុខសាន្ត នៅភូមិបេថ្លេហិម ដែលមានផ្ទៃមេឃងងឹត ដែលមានផ្កាយយ៉ាងច្រើន មានព្រះច័ន្ទដែលភ្លឺយ៉ាងស្អាត ដោយសារយប់នេះមានកូនង៉ែតម្នាក់ ដែលប្រសូតហើយ និងកូននេះជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលយាងមកឲ្យយើងទទួលជីវិតថ្មី យប់នេះមានអ្វីដែលកែប្រែអស់ហើយ។

បើយើងគិតពិចារណា ឆ្នាំនេះជាឆ្នាំ២០១៧ យើងត្រូវគិតពីឆ្នាំសូន្យ ជាឆ្នាំដែលឆ្នាំព្រះយេស៊ូប្រសូត។ ពិភពលោកទាំងមូល បានរិះគិតរួមគ្នា ឆ្នាំសូន្យជាឆ្នាំដែលព្រះយេស៊ូប្រសូត មានន័យថានៅថ្ងៃនេះ នៅក្នុងយប់នេះ នៅភូមិបេថ្លេហិម មានអ្វីដែលកើតឡើងដែលណែនាំឲ្យពិភពលោកទៅជាពិភពថ្មី។ យើងលែងគិតអំពីអាដាំ និងអេវ៉ា យើងលែងគិតអំពីកាអ៊ីន និងអាបែល យើងគិតអំពីគ្រួសារដ៏វិសុទ្ធថ្មី យើងមើលឃើញអំពីព្រះនាងម៉ារី យើងមើលឃើញលោកយ៉ូសែប យើងមើលឃើញកូនង៉ែតព្រះយេស៊ូ ដែលជាគ្រួសារដ៏វិសុទ្ធ ដែលណែនាំឲ្យមនុស្សលោកទៅជាមនុស្សថ្មី ។ មនុស្សលោកទៅជាមនុស្សលោកថ្មីសព្វថ្ងៃស៊ីសងយើងរៀងៗខ្លួន យើងទទួលក្នុងដៃរបស់យើង យើងទទួលនៅក្នុងត្រចៀកអស់ហើយ ដំណឹងល្អព្រះយេស៊ូប្រសូតហើយ។ យើងច្រៀងព្រះអម្ចាស់យេស៊ូប្រសូតហើយ យើងច្រៀងអស់ពីកម្លាំងកាយចិត្ត ប៉ុន្តែឥឡូវនេះធ្វើយ៉ាងមិចដើម្បីអនុវត្តន៍ នៅក្នុងជីវិតផ្ទាល់របស់យើង ដើម្បីឲ្យពាក្យសន្យាដែលយើងបានស្តាប់ ពីក្រុមព្យាការីទាំងឡាយ អេសាយ សាការី និងយ៉ូហានបាទីស្ទ ឲ្យទៅជាពាក្យសន្យាជាក់ស្តែង ដែលគេមើលឃើញនៅក្នុងពិភពលោកសព្វថ្ងៃ។ យើងបានស្តាប់ហើយ ឥឡូវនេះព្រះបន្ទូលកើតជាមនុស្សហើយព្រះបន្ទូលនេះ គង់នៅជាមួយយើង២០១៧ឆ្នាំកន្លងមក។ យើងទទួលទ្រព្យសម្បត្តិនេះយ៉ាងពិសេស នៅក្នុងដៃរបស់យើងទទួលព្រះយេស៊ូប្រសូតហើយ។

ឆ្នាំខ្ញុំសប្បាយចិត្តដោយសារ ខ្ញុំបានដើរតាមកន្លែងច្រើនណាស់ កន្លែងនីមួយៗមានឃើញព្រះកុមារយេស៊ូមួយស្អាត ជួនកាលធំណាស់ ធ្ងន់ ខ្ញុំចង់លើកមិនកើត។ ជួនកាលតូចល្មម ហើយនៅកន្លែងសាលាឡាវ៉ាឡា តូចមែនទែន ដូច្នេះនៅក្នុងដៃខ្ញុំ នាំឲ្យខ្ញុំកក់ក្តៅណាស់ ដូចជាព្រះយេស៊ូតូចនៅក្នុងដៃខ្ញុំ។ ខ្ញុំគិតថាពេលនេះ ខ្ញុំមានព្រះសង្គ្រោះនៅក្នុងដៃរបស់ខ្ញុំ ។ ប៉ុន្តែ មិនមែនតែរូបចំលាក់ឈើតែប៉ុណ្ណឹង គឺព្រះយេស៊ូពិតមែនដែលយាងមកនៅក្នុងជីវិតរបស់យើង ដើម្បីឲ្យយើងរស់នៅតាមរបៀបដែលព្រះយេស៊ូណែនាំយើង។

កូនង៉ែតដែលយើងគោរពយប់នេះ បន្តិចទៀតទៅជាគ្រូគង្វាលដ៏សប្បុរស ដូចលោកអេសាយបានសន្យាដល់យើង "**ព្រះអម្ចាស់កំពុងយាងមក ព្រះអម្ចាស់ដូចជាគ្រូគង្វាល ដែលឃ្វាលហ្វូងចៀមរបស់ខ្លួន។ ព្រះអង្គលើកព្រះហស្តឡើង ប្រមូលកូនចៀម ព្រះអង្គបីកូនតូចៗជាប់នឹងព្រះឱរ៉ា ហើយព្រះអង្គកំពុងថែទាំមេចៀមដែលកំពុងបំបៅកូនផងដែរ**" នេះជាព្រះយេស៊ូរបស់យើង។ យប់នេះជាកូនង៉ែត បន្តិចទៀតជាគ្រូគង្វាលដ៏សប្បុរស ដែលប្រមូលកូនចៀម ដែលថែរក្សាមេចៀម ដើម្បីរួមគ្នាយើងទទួលជីវិតថ្មី និងរួមគ្នាយើងទទួលកក់ក្តៅនៅក្នុងសេចក្តីស្រឡាញ់ និងព្រះហឫទ័យសន្តោសរបស់ព្រះជាម្ចាស់ផ្ទាល់។

សញ្ញា ដែលយើងឃើញ យើងបានស្តាប់នៅក្នុងលោកអេសាយ "**ពេលនោះមនុស្សខ្វាក់នឹងមើលឃើញ មនុស្សថ្លង់នឹងស្តាប់ឮ មនុស្សខ្វិននឹងលោតដូចប្រើស ហើយមនុស្សគរនឹងច្រៀងយ៉ាងរីករាយ ដ្បិតទឹកផុសឡើងនៅវាលរហោស្ថាន**" នេះជាសញ្ញាសម្គាល់ យើងឃើញគ្រីស្តបរិស័ទទទួលបេសកកម្មនេះ។ ប៉ុន្មានថ្ងៃមុនខ្ញុំបានចូលរួមបុណ្យព្រះយេស៊ូប្រសូត្រ ជាមួយកូនក្មេងពិការធ្ងន់ណាស់ ដើរមិនរួច និយាយមិនរួច មួយចំនួនអង្គុយមិនបាន ធ្វើកាយវិការក៏មិនបាន ប៉ុន្តែនៅសល់កាយវិការមួយ គឺញញឹមបាន។ នៅពេលយើងបានចែក តុក្កតាឲ្យម្នាក់មួយៗ គេសប្បាយចិត្តណាស់ គេឱបតុក្កតា ញញឹមអស់ពីសមត្ថភាពរបស់គេ។ ដូច្នេះមិនត្រូវការធ្វើអ្វីអស្ចារ្យ ប៉ុន្តែសញ្ញាតូចតាចណែនាំឲ្យមនុស្សដែលកំពុង រងទុក្ខលំបាកនៅក្នុងជីវិត មានជីវិតថ្មី។

ប៉ុន្មានថ្ងៃមុន យើងបានទៅមន្ទីឃុំឃាំងនៅខេត្តកំពត ឆ្នាំនេះមនុស្សច្រើនណាស់ ពី៣០០នាក់ទៅ៧០០នាក់ កំពង់សោមឡើងពី៥០០នាក់ទៅ១១០០នាក់។ យើងមានជួបគេជាមួយព្រះសង្ឃ ជាមួយអ៊ីមាំខាងឥស្លាម យើងបានចែកម្ហូបអាហារ ចែកភួយ...។ ខ្ញុំឃើញនៅពេលនោះគេសប្បាយចិត្តណាស់ និងគេនិយាយដូចនេះ ឈរយូរសប្បាយចិត្តណាស់ ដោយសារយើងជាប់នៅក្នុងបន្ទប់ចង្អៀត មិនដែលចេញសោះ។ ៥០នាក់នៅក្នុងបន្ទប់មួយដែលបិទទ្វារចាក់សោរ នៅក្នុងភាពងងឹត ថ្ងៃនោះមានព្រះអាទិត្យភ្លឺយ៉ាងស្អាត គេចេញពីបន្ទប់គេឈរយូរ ដោយសារយើងមានសុន្ទរកថា យើងចែកម្នាក់ម្តងៗ យើងបានប្រោះទឹកព្រះពរគេសប្បាយចិត្តណាស់។ គេថាសប្បាយចិត្ត ដោយសារគេបានឈរម្តង នេះមានអត្ថន័យច្រើន មិនមែនឈរដោយសារស្ពឹកជើង ប៉ុន្តែឈរនៅក្នុងខ្លួន ដោយសារជីវិតគេមានតម្លៃថ្លៃថ្នូរ នៅពេលយើងចូលដើម្បីសួរសុខទុក្ខ ជាលក្ខណៈសាសនា គេថាជីវិតគេមិនមែន

ជីវិតដែលភ្ជាប់នៅក្នុងមន្ទីរឃុំឃាំង បិទសិទ្ធិសេរីភាពទៅខាងក្រៅ ប៉ុន្តែនៅខាងក្នុងមានទ្រព្យសម្បត្តិមួយដ៏ពិសេស គឺជីវិតថ្លៃថ្នូរដែលគេបានទទួល។ ខ្ញុំជឿថានៅពេលនោះ យើងបានសម្តែងសក្ខីភាពមួយយ៉ាងពិសេស គឺមនុស្សយើងមានតម្លៃណាស់ និងជីវិតរបស់យើងមានសេចក្តីសង្ឃឹមជានិច្ច។ យើងជាគ្រីស្តបរិស័ទ ក្នុងយប់បុណ្យព្រះយេស៊ូប្រសូត យើងបានទទួលពាក្យសន្យារបស់ព្រះអង្គ ដែលណែនាំឲ្យយើងពោរពេញដោយសេចក្តីសង្ឃឹម មនុស្សយើងបើអស់សង្ឃឹម លែងធ្វើអ្វីបាន។

ព្រឹកមិញនៅសាលាឡាវ៉ាឡា កូនក្មេង៣៥០នាក់ច្រើនណាស់ គេនៅលើរទេះរបស់គេ ខ្លះមានជើងមួយ ខ្លះមានដៃមួយ ប៉ុន្តែគេសប្បាយចិត្តណាស់។ ខ្ញុំសួរសំណួរនេះ តើប្អូនមានសេចក្តីសង្ឃឹមសម្រាប់អនាគតឬទេ? គេស្រែកទាំងអស់គ្នាយ៉ាងខ្លាំង យើងមានសេចក្តីសង្ឃឹម។ គេកំពុងរៀន គេដឹងថាពេលក្រោយគេអាចរកការងារខ្លះៗ ដោយសារគេមានគ្រួសារមួយដែលស្រឡាញ់គេ ដែលនាំឲ្យគេកក់ក្តៅ។

ជីវិតយើងជាគ្រីស្តបរិស័ទ ជាពិសេសយប់នេះ យើងត្រូវការប្រមូលសេចក្តីសង្ឃឹមនៅក្នុងដួងចិត្តរបស់យើងដល់កំពូល ដើម្បីពេញមួយឆ្នាំខាងមុខយើងអាចចែកសេក្តីសង្ឃឹមនេះជាមួយបង្អូនឯទៀតៗ។ ពិតមែន យើងជាមនុស្សថ្មី យើងបានស្តាប់នៅក្នុងវជ្ជរវង់ចាំ **"រីឯអ្នកដែលជឿសង្ឃឹមលើព្រះអង្គម្ចាស់ តែងតែមានកម្លាំងថ្មីជានិច្ច ប្រៀបបាននឹងសព្វឥន្ទ្រីហោះហើរ គេស្ទុះរត់ទៅមុខដោយមិនចេះហត់ ហើយដើរដោយមិនចេះអស់កម្លាំង"**នេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ ដូច្នេះសម្រាប់ឆ្នាំខាងមុខនេះ ដែលទទួលកម្លាំងពីព្រះពន្លឺដោយសារព្រះបន្ទូលកើតជាមនុស្ស ដោយយើងទទួលសេចក្តីសង្ឃឹម ដោយសារព្រះយេស៊ូយ៉ាងមកដើម្បីឲ្យភាពងងឹតនៃជីវិតយើងផ្លាស់ ទៅជាពន្លឺមួយយ៉ាងពិសេសអស្ចារ្យ។ យើងជឿថាពិតមែន យើងទទួលកម្លាំងថ្មីជានិច្ច ប្រៀបដូចជាសព្វឥន្ទ្រី និងយើងទៅជាមនុស្សដែលមិនចេះហត់ ដែលមិនចេះអស់កម្លាំង ដោយសារយើងមានព្រះយេស៊ូ។

នៅពេលនេះយើងអរព្រះគុណព្រះជាម្ចាស់ យើងសុំព្រះអង្គគង់នៅជាមួយយើងដើម្បីឲ្យយើងរស់នៅក្នុងអំណរសប្បាយយ៉ាងពិសេស ពិតមែនព្រះយេស៊ូប្រសូត ពិតមែនព្រះយេស៊ូយាងមក ដើម្បីសង្គ្រោះមនុស្សទាំងអស់ ដោយសារព្រះជាម្ចាស់ដែលជាព្រះបិតា ស្រឡាញ់យើងយ៉ាងខ្លាំងណាស់។ អាម៉ែន៕